AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

# កុម្ភកាណ៌ក្នុងសិល្បៈទស្សនីយភាពខ្មែរ

គេចាត់ទុករឿងរាមាយណៈ ជារឿងមួយដែលមានប្រជាប្រិយភាពខ្លាំងនៅក្នុងចំណោមរឿងធំៗឯទៀតក្នុងពិភពលោក។ ប្រជាប្រិយភាពនេះ មានផ្ទុះបង្ហាញ ដូចជានៅក្នុងការយកទៅប្រើប្រាស់ដោយច្នៃប្រឌិតនូវអន្ទើខ្លះនៅក្នុងរឿងរាមាយណៈ ទៅតាមដំបន់និងប្រទេសដែលធ្វើឥណ្ឌាភាវូបនីយកម្ម។

សិល្បករសិល្បការិនី ខ្មែរ យករឿងរាមកេរ្តិ៍(រាមាយណៈ) ជាប្រធានបទធំមួយដើម្បីបង្កើតនិងអភិវឌ្ឍសិល្បៈរូបីនិងអរូបី រួមមានចម្លាក់ សូនរូប គំនូរលើក្រដាសឬជញ្ជាំង ការបោះពុម្ពលើក្រដាសឬក្រណាត់ ល្ខោនក្បាច់បុរាណ ល្ខោនខោល ល្ខោនស្បែក ចម្រៀងចាប៉ី និទានរឿង និងហោរាសាស្ត្រ។ នៅក្នុងអត្ថបទដ៏ខ្លីនេះ ខ្ញុំសូមនិយាយសង្ខេបពាក់ព័ន្ធតែអំពីទម្រង់ល្ខោនខោលនិងការប្រើរឿងរាមកេរ្តិ៍
ដោយផ្តោតជាពិសេសទៅលើតួអង្គកុម្ភកាណ៌។

ល្ខោនខោល ជាទម្រង់ល្ខោនប្រុសពាក់មុខ ដោយអ្នករាំធ្វើកាយវិការឥតព្រាងទុកទៅតាមពាក្យសម្តីរបស់អ្នកពោល ដែលជាអ្នកដឹករឿង។ ឈុតនិងសាច់រឿងល្ខោនខោលច្រើនពាក់ព័ន្ធនឹងចម្បាំងរវាងពួកយក្សនិងស្វា ហើយសម្តែងតែរឿងរាមកេរ្តិ៍មួយប៉ុណ្ណោះ ដោយគេជ្រើសរើសយកឈុតណាមួយមកសម្តែង ដូចជាឈុតកុម្ភកាណ៌ទប់ទឹកជាដើម។

នាអតីតកាល គេសម្តែងល្ខោនខោលនៅក្នុងពិធីបុណ្យជាតិនិងសាសនាផ្សេងៗ ក៏ដូចជានៅពេលមានភ័យន្តរាយរាំងស្ងួតផងដែរ ដើម្បីបួងសួងសូមទឹកភ្លៀងសម្រាប់ភូមិស្ថាននិងដំណាំកសិកម្មរបស់គេ។ នៅក្នុងបរិបទនេះ គេសម្តែងឈុត «កុម្ភកាណ៌ទប់ទឹក» ដោយគេមានជំនឿថា កុម្ភកាណ៌ ជាស្តេចយក្សបានពង្រីកខ្លួនយ៉ាងធំដើម្បីនឹងទប់ទឹកកុំឲ្យហូរ ដូច្នេះហើយបានជាមានការរាំងស្ងួត។ ក្រោយពីកុម្ភកាណ៌បានស្លាប់ (នៅក្នុងឈុតនិងសាច់រឿង) ទើបទំនប់ទឹករបើកធ្វើឲ្យទឹកហូរជាធម្មតាឡើងវិញ។ ខ្ញុំគួរធ្វើការកត់សម្គាល់ថា នៅក្នុងរឿងរាមាយណៈ កុម្ភកាណ៌ មិនត្រូវបានគេសម្លាប់នៅពេលទប់ទឹកនេះឡើយ តែត្រូវបានព្រះលក្ស្មណ៍សម្លាប់ទៅវិញ។[១]

---

[១] Sam 2004: 103

អត្ថបទដោយ៖

កុម្ភកាណ៌ ជាយក្សមួយដ៏ធំសំបើមដែលមានមុខបួនពណ៌បៃតងខ្ចី និងជាប្អូនប្រុសរបស់រាពណ៍។[២] «កុម្ភៈ» មានន័យថា «ក្អម ឬផ្ទាំង» ហើយ «កាណ៌» មានន័យថា «ត្រចៀក»។ ដូច្នេះ «កុម្ភកាណ៌» មានន័យថា «មានត្រចៀកដូចក្អមឬផ្ទាំង»។[៣] កុម្ភកាណ៌ ជាឧត្តមសេនីយនៅក្នុងជួរកងទ័ពក្រុងលង្កា។ ព្រះព្រហ្មបានផ្តល់ឲ្យ គាត់នូវដំបងដ៏ ពិសិដ្ឋក្លាំងក្លាមួយ។[៤] នៅក្នុងរឿងរាមកេរ្តិ៍ខ្មែរ កុម្ភកាណ៌ត្រូវបានស្លាប់ដោយ ព្រះលក្ស្មណ៍សម្លាប់។[៥] ឯនៅក្នុងរឿងរាមាយណៈឥណ្ឌា និងរឿងរ៉ាម៉ាគៀនថៃវិញ កុម្ភកាណ៌ត្រូវបានស្លាប់នៅក្នុងសង្គ្រាមដោយព្រះរាមសម្លាប់។[៦]

**គ្រួសារវិស្រវ-សេធាន**




អរិយធម៌ខ្មែរ
KHMER CIVILIZATION

[២] Sam 2004: 103

[៣] *Reamker* 1964: 3-5; Chuon Nath: 1967: 42; Sam 2004: 103

[៤] Chheng 1998: 36

[៥] Chheng 1998: 39; Sam 2004: 103

[៦] King Rama I, 2002 [1807]: 73; Beach 1983: 46; Narayan 1972: 148; Gaer 1954: 159; Sam 2004: 103

អត្ថបទដោយ៖

ឯកសារពិគ្រោះ

ជួន ណាត. (១៩៦៧). *វចនានុក្រមខ្មែរ*. ភ្នំពេញ: ពុទ្ធសាសនបណ្ឌិត្យ។
ពេជ្រ ទុំក្រវិល. (២០០៣). *ទស្សនីយភាពខ្មែរ*. ភ្នំពេញ: រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖